**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**
លេខ: ៦២៩ សជណ...ប.ស្ក

ថ្ងៃច័ន្ទ ៥កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី០២ ខែ កក្កដា ឆ្នាំ២០១៨

**ជម្រាបជូន**
**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**
**ទទួលបន្ទុកជាប្រធានអគ្គនាយកកំពង់ផែស្វយ័តក្រុងព្រះសីហនុ**

**កម្មវត្ថុ ៖** ករណីសំណើសុំពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ សម្រាប់គម្រោងអភិវឌ្ឍន៍ចំណតផែកុងតេន័រថ្មី នៅខេត្តព្រះសីហនុ

**យោង ៖**
- ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- អនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- លិខិតលេខ ១៣៦៦ កសស.NCT ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦ របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ
- លិខិតលេខ ៨១៣ វ.ហ.ប.ស្ក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ របស់នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៃក្រសួងបរិស្ថាន
- លិខិតលេខ ៩៣៧ កសស.NCT ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៧ របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ
- លិខិតលេខ ១៦២ សជណ ប.ស្ក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៨ របស់ក្រសួងបរិស្ថាន
- លិខិតលេខ ៤៣០ កសស.NCT ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៨ របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម** មេត្តាជ្រាបថា ក្រសួងបរិស្ថានឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ សម្រាប់គម្រោងអភិវឌ្ឍន៍ចំណតផែកុងតេន័រថ្មី លើផ្ទៃដីទំហំ ១៧,៥ហិកតា ដែលមានទីតាំងស្ថិតនៅសង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ ដោយ **ឯកឧត្តម** ត្រូវគោរពកិច្ចសន្យាការពារបរិស្ថាន ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨ របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម** អនុវត្ត និងចាត់ចែងតាមការគួរ។
សូម **ឯកឧត្តម** ទទួលនូវសេចក្តីរាប់អានពីខ្ញុំ។

**រដ្ឋមន្ត្រី**

**សាយ សំអាល់**

<u>ចម្លងជូន៖</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងធនធានទឹក និងឧតុនិយម
- ក្រសួងទេសចរណ៍
- រដ្ឋបាលខេត្តព្រះសីហនុ
- មន្ទីរបរិស្ថានខេត្តព្រះសីហនុ
- ឯកសារ កាលប្បវត្តិ

អាគារមរតកតេជោ ដីឡូលេខ503 ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ: 023 235 004 / 023 235 006